# វគ្គបណ្តុះបណ្តាលគ្រូបង្គោល
# ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម
## សន្ទរកថាបើក
## ឯកឧត្តម ឌី ច័ន្ទផល
រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

ប្រធានគណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម

ថ្ងៃទី០៦-០៨ ខែមេសា ឆ្នាំ២០១៦ - នៅខេត្តបាត់ដំបង

**ឯកឧត្តម លោកជំទាវ គណៈអធិបតី**

**អស់លោក លោកស្រី អង្គពិធីទាំងមូល ជាទីមេត្រី**

ក្នុងនាម **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងថ្នាក់ដឹកនាំ ខ្ញុំមានបិតិសោមនស្សរីករាយ និងមានកិត្តិយសបានមកចូលរួមថ្លែងសន្ទរកថាបើក ក្នុងវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ខេត្ត ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម ដែលបានរៀបចំដោយលេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងគោលបំណងបង្កើនសមត្ថភាព ចំណេះដឹង និងជំនាញ ដល់សិក្ខាកាមដែលជាគ្រូបង្គោល ដើម្បីយកទៅធ្វើការបណ្តុះបណ្តាលបន្តដល់អ្នកពាក់ព័ន្ធមកពី១៤ ខេត្ត និង ៥៤ស្រុកគោលដៅទាំងអស់ដែលនឹងត្រូវអនុវត្តការងារគណនេយ្យភាពសង្គមនៅក្នុងឆ្នាំ ២០១៦នេះ។

ឆ្នាំ២០១៦នេះ ជាឆ្នាំទី៣នៃការអនុវត្តន៍កម្មវិធីកំណែទម្រង់ជាអាទិភាពដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៥នៃរដ្ឋសភា។ អនុញ្ញាតិឲ្យខ្ញុំបញ្ជាក់ជាសារបានសង្ខេបពីឆន្ទៈរបស់រាជរដ្ឋាភិបាល ជាយុទ្ធសាស្ត្រ ជាគោលនយោបាយ ជាសកម្មភាពអាទិភាព ក្នុងការជម្រុញការងារកំណែទម្រង់ដ៏មានសារៈសំខាន់នេះ។

## យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ (២០១៣-២០១៨) ដើម្បី **កំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព** បានដាក់ចេញនូវ **គោលដៅយុទ្ធសាស្ត្រ ៤** និង **វិស័យអាទិភាព៤** ដើម្បីឆ្លុះបញ្ចាំងពីឆន្ទៈផ្ដេជ្ញាចិត្តក្នុងការអនុវត្ត រយៈពេល៥ឆ្នាំទៅមុខ។ **គោលដៅទី៤- គឺបន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ចនៃស្ថាប័នរដ្ឋទាំងថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃសេវាសាធារណៈ សំដៅបម្រើប្រជាជនឱ្យកាន់តែប្រសើរឡើង។** គោលនយោបាយ កម្មវិធីជាតិ និងសកម្មភាពជាច្រើនបានអនុវត្តពង្រឹង និងពង្រីក ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច **ដើម្បី កំណើន និងការងារ** ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសង្គម **ដើម្បីសមធម៌** និង ពង្រឹងហេដ្ឋារចនាសម្ព័ន្ធប្រជាធិបតេយ្យ **ដើម្បីប្រសិទ្ធភាព**។